

www.kidsofdestiny.org
Kids of Destiny®
Reaching the Next Generation

## 2.06 **ការចាប់ដ៏អស្ចារ្យ**

នៅថ្ងៃមួយ ព្រះយេស៊ូវទ្រង់បានកំពុងតែបង្រៀនមនុស្សជាច្រើន។ ព្រះយេស៊ូវទ្រង់សព្វព្រះហឫទ័យនឹងបង្រៀនបណ្ដាហ្វូងមនុស្សណាស់ ហើយហ្វូងមនុស្សក៏ចូលចិត្តស្ដាប់មេរៀនរបស់ទ្រង់ដែរ។ នៅថ្ងៃនោះ ពួកគេទាំងអស់គ្នាបានកំពុងតែអង្គុយក្បែរមាត់សមុទ្រ ហើយព្រះយេស៊ូវទ្រង់កំពុងឈរនៅមុខពួកគេ។ តែវាពិតជាពិបាក សម្រាប់ហ្វូងមនុស្សជាច្រើននេះ ដើម្បីនឹងឮព្រះបន្ទូលទ្រង់ ដូច្នេះពួកគេបានរុញនិងប្រជ្រៀតគ្នា ដើម្បីបាន មកជិតទ្រង់។ តើព្រះយេស៊ូវទ្រង់អាចនឹងធ្វើអ្វីដើម្បីដោះស្រាយបញ្ហាទាំងនេះ? ទ្រង់ក៏ក្រឡេកមើលជុំវិញខ្លួន ហើយក៏បានឃើញទូកពីរចតនៅមាត់សមុទ្រ។ ដែលពួកអ្នកនេសាទបានឡើងទៅលាងអួនហើយ។ បន្ទាប់មកទ្រង់បានសម្រេចចិត្តចុះក្នុងទូកមួយក្នុងចំណោមទូកទាំងពីរនោះដើម្បីបង្រៀនពួកគេ។ ប្រហែលជាឥឡូវនេះ មនុស្សទាំងអស់អាចឮពីទ្រង់កាន់តែច្បាស់ ។ នេះពិតជាគំនិតដ៏ល្អមែន! ក៏សូមឲ្យអ្នកនេសាទម្នាក់ឈ្មោះស៊ីម៉ូន ចេញទូកពីច្រាំងបន្តិច ។ ដោយទ្រង់គង់ក្នុងទូកស៊ីម៉ូន ដូច្នេះហ្វូងមនុស្សអាចឮទ្រង់បង្រៀនគ្រប់គ្នាបាន ។ ទ្រង់ក៏អាចមើលឃើញ និងមានបន្ទូលទៅកាន់ហ្វូងមនុស្សគ្រប់គ្នាបាន ព្រះអង្គក៏អង្គុយចុះនៅលើទូក ហើយបង្រៀនប្រជាជន ។ នៅពេលដែលទ្រង់បង្រៀនចប់ហើយ ទ្រង់ក៏បែរទៅរកស៊ីម៉ូនជាអ្នកនេសាទនោះ ហើយមានបន្ទូលថា "ចូរចេញទូករបស់អ្នកទៅឯទឹកជ្រៅ ហើយទំលាក់អួនដើម្បីចាប់ត្រីខ្លះចុះ" ។ ស៊ីម៉ូនពិតជាអស់កម្លាំងណាស់។ ព្រោះគាត់និងមិត្តភក្តិរបស់គាត់ បាននេសាទពេញមួយយប់ហើយ តែមិនបានអ្វីសោះ។ ប៉ុន្តែគាត់ចង់ផ្គាប់ចិត្តព្រះយេស៊ូវ ។ លោកស៊ីម៉ូនក៏ទូលព្រះអង្គថា៖ «យើងបានរកវាពេញមួយយប់ហើយ ។ តែយើងមិនចាប់បានអ្វីសោះ ប៉ុន្តែដោយសារលោកបានស្នើសុំខ្ញុំដូច្នេះ ខ្ញុំនឹងសាកម្តងទៀត ។ ស៊ីម៉ូននិងមិត្តភក្តិរបស់គាត់ បានធ្វើដូចព្រះយេស៊ូវទ្រង់បានមានបន្ទូល ។ ពួកគេបានចេញទូករបស់ពួកគេទៅឯទឹកជ្រៅ។ ពួកគេក៏បានទម្លាក់អួនរបស់ពួកគេភ្លាម ហើយវាពិតជាគួរឱ្យភ្ញាក់ផ្អើលខ្លាំងណាស់! ត្រីជាច្រើនបានជាប់នៅក្នុងអួនរបស់ពួកគេ! ពួកគេបានប្រឹងទាញ ហើយទាញទៀត ។ ហើយពួកគេបានហៅគូកនដែលនៅក្នុងទូករបស់ពួកគេ១ទៀត ដើម្បីមកជួយទាញពួកគេ ព្រោះជាប់បានត្រីធ្ងន់សន្ធឹកពេក។ ពួកគេទាំងអស់គ្នាក៏បានជួយគ្នា ហើយទាញយកត្រីដាក់ចូលក្នុងទូកពួកគេទាំងពីរ។ ទូកក៏ពៀបស្ទើរនឹងលិច ដោយសារត្រីច្រើនពេក ។ ស៊ីម៉ូនបានក្រាបចុះនៅទៀបព្រះបាទាព្រះយេស៊ូវ ហើយទូលថា៖ «ឱព្រះអម្ចាស់អើយ! សូមទ្រង់យាងឲ្យឆ្ងាយពីទូលបង្គំទៅ ព្រោះទូលបង្គំជាមនុស្សមានបាប!»។ គាត់ទូលដូច្នោះដោយហេតុគាត់ និងពួកអ្នកនៅជា មួយយ៉ាកុបនិងយ៉ូហាននឹកស្ញើចក្នុងចិត្តពីត្រីដែលបានច្រើនដល់ម្ល៉េះ ។ ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលទៅស៊ីម៉ូនថា៖ «កុំខ្លាចអី ពីនេះទៅមុខអ្នកនឹងចាប់មនុស្សវិញ" ។ ព្រះយេស៊ូវទ្រង់មិនចង់ឲ្យស៊ីម៉ូនខ្លាចអ្វី ដែលកំពុងបានកើតឡើងនោះទេ ប៉ុន្តែ ដើម្បីឲ្យដឹងថាទ្រង់មានផែនការល្អសម្រាប់ជីវិតរបស់គាត់ ។ បន្ទាប់ពីស៊ីម៉ូននិងគូកនរបស់គាត់បានចតទូកមកលើគោកហើយ ពួកគេបានងាកចេញពីជីវិតចាស់របស់ពួកគេ ដែលជាអ្នកនេសាទនោះ ហើយបែរមកក្លាយជាអ្នកដើរតាមព្រះយេស៊ូវវិញ ។ **(លូកា ៥)**

## 2.06 ការចាប់ដ៏អស្ចារ្យ - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន

**កំណត់សម្គាល់**:

1) ព្រះយេស៊ូវទ្រង់សព្វព្រះទ័យនឹងនិទានរឿង ។ ព្រោះទ្រង់សព្វព្រះទ័យនឹងបង្រៀនហ្វូងមនុស្សតាមរយៈរឿងទាំងនោះ ។ ដូចជាថ្ងៃនេះផងដែរ ដែលខ្ញុំបានកំពុងតែបង្រៀនអ្នកទាំងអស់គ្នា ។ នៅថ្ងៃនេះព្រះយេស៊ូវបានមានមនុស្សមួយហ្វូងធំ ដែលចង់ស្តាប់ទ្រង់ ដូច្នេះទ្រង់ត្រូវការកន្លែងឈរ ឬអង្គុយ ដើម្បីឲ្យមនុស្សគ្រប់គ្នាអាចមើលឃើញ និងស្តាប់ទ្រង់បាន ។ តើអ្នកទាំងអស់គ្នាអាចស្តាប់ខ្ញុំឮទេ? តើអ្នកទាំងអស់គ្នាអាចមើលឃើញខ្ញុំទេ? រឿងនេះនឹងកាន់តែគួរឱ្យរំភើប ប្រសិនបើអ្នកទាំងអស់គ្នាអាចមើលឃើញ និងស្តាប់ឮអ្វីៗទាំងអស់ដែលកំពុងនឹងកើតឡើង ។

2) ព្រះយេស៊ូវទ្រង់ត្រូវការប្រើទូកនៅថ្ងៃនេះ ដើម្បីឱ្យមនុស្សគ្រប់គ្នាបានឃើញ និងស្តាប់ទ្រង់ឮ ។

3) អ្នកនេសាទទាំងនោះបានអស់កម្លាំងណាស់ ។ ព្រោះពួកគេបាននេសាទពេញមួយយប់ហើយ ។ នៅពេលដែលយើងខំប្រឹងធ្វើការអ្វីមួយ យើងអាចនឹងនឿយហត់ មែនទេ? ពេលព្រះយេស៊ូវសុំឲ្យពួកគេឲ្យដាក់អួនរបស់ពួកគេម្តងទៀត ពួកគេគ្រាន់តែសាកម្តងទៀត ពីព្រោះទ្រង់បានសុំពួកគេ ។

4) ព្រះយេស៊ូវទ្រង់ជ្រាបនូវអ្វីៗ ដែលយើងមិនដឹង ។ ជាការល្អ ដែលស្តាប់តាមទ្រង់ ។ ទ្រង់តែងតែមានគំនិតល្អបំផុតសម្រាប់យើង ។

**សំណួរ**:

1) នៅថ្ងៃនេះ តើប្រជាជនបានប្រមូលផ្តុំគ្នាដើម្បីស្តាប់ព្រះយេស៊ូវនៅកន្លែងណា?
2) តើព្រះយេស៊ូវបានធ្វើអ្វីខ្លះ ដើម្បីឱ្យមនុស្សគ្រប់គ្នាអាចស្តាប់ឮទ្រង់បាន?
3) តើព្រះយេស៊ូវទ្រង់បានប្រាប់អ្នកនេសាទទាំងនោះឲ្យធ្វើអ្វី?
4) តើមានអ្វីកើតឡើងនៅពេលដែលអ្នកនេសាទទាំងនោះ ចេញទៅទម្លាក់អួនរបស់ពួកគេម្តងទៀត?
5) តើព្រះយេស៊ូវទ្រង់បានប្រាប់ស៊ីម៉ូនអំពីអ្វី? តើនេះមានន័យយ៉ាងម៉េច?

**ចម្លើយ**:

1) ពួកគេបានប្រមូលផ្តុំគ្នានៅមាត់ច្រាំង ។
2) ព្រះយេស៊ូវទ្រង់បានយាងចុះទៅក្នុងទូក ។
3) ព្រះយេស៊ូវទ្រង់បានប្រាប់អ្នកនេសាទទាំងនោះឲ្យទំលាក់អួនរបស់ពួកគេចុះ ។
4) ពេលនោះចាប់បានត្រីសន្ធឹកណាស់ ដូច្នេះគឺត្រូវការទូកពីរ ដើម្បីដាក់ត្រីទាំងអស់បាន ។
5) ព្រះយេស៊ូវទ្រង់បានប្រាប់ស៊ីម៉ូនថា ឥឡូវនេះគាត់នឹងចាប់មនុស្សជំនួសត្រីវិញ ។ ឥឡូវនេះស៊ីម៉ូននឹងទៅជាមួយព្រះយេស៊ូវ ដើម្បីនៅជាមួយទ្រង់ដូចដែលព្រះយេស៊ូវបានប្រាប់ប្រជាជនអំពីព្រះ ។


Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org